**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៧៨៩ ព.ណ.កសរ..

ថ្ងៃ ចន្ទ ១៥រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ២០២០

**ជម្រាបជូន**

- **លោកប្រធានសហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា (CAIF)**
- **លោកប្រធានសមាគមអ្នកលក់យានយន្តកម្ពុជា (CADA)**

**កម្មវត្ថុ ៖** ការកំណត់លក្ខណៈសម្បត្តិយានយន្តថ្មី ពាក់ព័ន្ធនឹងការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ។

**យោង ៖**
- ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- សារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ស្តីពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក
- ប្រកាសលេខ ១៨៦ ព.ណ កសប.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីនីតិវិធីសម្រាប់ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកប្រធាន** ថា ការតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខនៅក្រសួងពាណិជ្ជកម្ម មានលក្ខខណ្ឌ និងវិសាលភាព ដូចខាងក្រោម៖

- ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និងការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ គ្របដណ្តប់តែលើទំនិញសុទ្ធនិងថ្មី ដែលមិនទាន់បានដាក់លក់ជាលើកដំបូងក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា។
- សិទ្ធិផ្តាច់មុខដែលទទួលបានពីការចុះបញ្ជី អាចផ្ទេរទៅឱ្យភាគីណាមួយបាន លុះត្រាតែមានការយល់ព្រមពីម្ចាស់ម៉ាក និងធ្វើការកត់ត្រា និងតម្កល់នៅក្រសួងពាណិជ្ជកម្ម ជាមុន។
- អ្នកទទួលសិទ្ធិផ្តាច់មុខ ស្របតាមមាត្រា ៣ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ អាចដាក់ពាក្យស្នើសុំកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល ៣(បី)ខែ យ៉ាងយូរ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃលិខិតប្រគល់សិទ្ធិពីម្ចាស់ម៉ាក។
- ក្នុងករណីម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិស្របច្បាប់ចង់ទទួលបាននូវការការពារសិទ្ធិផ្តាច់មុខលើការនាំចូល និងចែកចាយនូវគ្រប់ម៉ូដែល ឬផលបត្រម៉ាក (Trademark Portfolio) ដែលជ្រកក្រោមម៉ាកតែមួយ ត្រូវស្នើសុំកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខនៅក្រសួងពាណិជ្ជកម្ម នូវគ្រប់ម៉ូដែលទាំងអស់ ឬផលបត្រម៉ាក (Trademark Portfolio) ដែលជ្រកក្រោមម៉ាកនោះ។

បន្ទាប់ពីបានពិនិត្យលើលិខិតរបស់ **លោកប្រធាន** និងលទ្ធផលនៃកិច្ចប្រជុំជាបន្តបន្ទាប់កន្លងមក ក្រសួងពាណិជ្ជកម្ម សូមសម្រេចកំណត់នូវលក្ខណៈសម្បត្តិនៃយានយន្តថ្មី ដូចខាងក្រោម៖

១- មិនត្រូវបានចុះបញ្ជី ឬផ្ទេរកម្មសិទ្ធិយានយន្ត ដោយអាជ្ញាធរមានសមត្ថកិច្ចនៅប្រទេសណាមួយនៅឡើយ ឬ



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

២- មិនត្រូវបានលក់ ឬជួល លើកដំបូងបង្អស់ ពីក្រុមហ៊ុនផលិតយានយន្ត ក្រុមហ៊ុននាំចូលយានយន្ត ក្រុមហ៊ុនចែកចាយ ឬលក់យានយន្ត ឬភ្នាក់ងាររបស់ក្រុមហ៊ុនទាំងអស់នេះ ទៅឱ្យអ្នកប្រើប្រាស់ ឬ

៣- ត្រូវមានម៉ូដែលក្នុងឆ្នាំបច្ចុប្បន្នភាពនៃឆ្នាំម៉ូដែលរថយន្ត ឬម៉ូដែលមុន ឬក្រោយឆ្នាំបច្ចុប្បន្នភាពមួយឆ្នាំ ឬ

៤- ត្រូវមានឆ្នាំផលិតក្នុងឆ្នាំបច្ចុប្បន្ន ឬផលិតមុន ឬក្រោយឆ្នាំបច្ចុប្បន្នមួយឆ្នាំ (ឧទាហរណ៍នៃចំណុច ៣ និង ចំណុច ៤ ក្នុងករណីយានយន្តមានម៉ូដែល ឬផលិតនៅឆ្នាំ២០២០ ត្រូវគិតចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ ២០២១)។

ទន្ទឹមនេះ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** ថា ក្រសួងពាណិជ្ជកម្មនឹងបន្តពន្យល់ និងដោះស្រាយក្តីកង្វល់របស់ភាគីទាំងពីរតាមគោលការណ៍ច្បាប់ និងបទប្បញ្ញត្តិនានាជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា នៅពេលក្រោយជាបន្តបន្ទាប់ទៀត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** ជ្រាប និងអនុវត្តតាមការគួរ។

សូម **លោកប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**ចម្លងជូន៖**

- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកសារ កាលប្បវត្តិ